# របាយការណ៍រួមស្ដីពីកម្ពុជារបស់ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា[1]
# ក្នុងបរិបទនៃការពិនិត្យជាសកលតាមកាលកំណត់ (UPR) លើរបាយការណ៍កម្ពុជា ជុំទីបី
# សំណៅចុងក្រោយ

## ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨

មាតិកា


កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសន្ធិសញ្ញា និងយន្តការសិទ្ធិមនុស្ស រួមទាំងនីតិវិធីពិសេស ..... ២
ការបង្កើតយន្តការបង្ការថ្នាក់ជាតិ ..... ២
ការអប់រំអំពីសិទ្ធិមនុស្សនិងសន្ធិសញ្ញានានា ..... ៣
កំណែទម្រង់ច្បាប់ ..... ៣
ឯករាជ្យភាពនៃតុលាការ និងការទទួលបានយុត្តិធម៌ ..... ៥
និទណ្ឌភាព ..... ៦
សេរីភាពជាមូលដ្ឋាន ..... ៦
កំណែទម្រង់ការបោះឆ្នោត និងការចូលរួមក្នុងជីវភាពនយោបាយ ..... ៨
អ.វ.ត.ក ..... ៨
ការឃុំខ្លួន និងលក្ខខណ្ឌក្នុងពន្ធនាគារ ..... ៨
ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ..... ៩
ការទទួលខុសត្រូវរបស់ធុរកិច្ច ការងារ ..... ១០
សិទ្ធិដីធ្លីនិងសិទ្ធិលំនៅដ្ឋាន ..... ១១
សុខភាព រួមទាំងមេរោគអេដស៍ ..... ១២
អប់រំ ..... ១៥
បណ្ដាញសុវត្ថិភាព ..... ១៥
កុមារ ..... ១៦
ស្ត្រី ..... ១៧
ក្រុមជនភាគតិច/ក្រុមសាសនាភាគតិច ..... ២០
ជនពិការ ..... ២០
ការជួញដូរមនុស្ស ..... ២១

**កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសន្ធិសញ្ញា និងយន្តការសិទ្ធិមនុស្ស រួមទាំងនីតិវិធីពិសេស (118.44-118.47)**

១. គិតត្រឹមខែឧសភា ឆ្នាំ២០១៨ ប្រទេសកម្ពុជាមិនទាន់បានដាក់របាយការណ៍ ឬការឆ្លើយតបតាមកាលកំណត់ ឬការតាមដានបន្តដែលផុតកាលបរិច្ឆេទកំណត់ ចំនួន៥ ជូនទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅឡើយទេ។[2]

២. ក្នុងឆ្នាំ២០១៧ និង២០១៨ អង្គការសហប្រជាជាតិ បានគាំទ្រដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងការរៀបចំរបាយការណ៍ក្រោមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ហើយក្នុងខែមិថុនា ឆ្នាំ២០១៧ បានគាំទ្រដល់ការរៀបចំសន្និសីទមួយស្តីពីការតាមដានបន្តទៅលើអនុសាសន៍ដែលបានទទួលមកពីវដ្តការពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទីពីរ។[3] ក្នុងឆ្នាំ២០១៥ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW) ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ និងគណៈកម្មាធិការ ស៊ី ដ បានរៀបចំកិច្ចសន្ទនាមួយជាមួយគណៈកម្មាធិការបច្ចេកទេសទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារនៃព្រឹទ្ធសភា និងគណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ី ដ នៃរដ្ឋសភា រួមទាំងបានពិភាក្សាអំពីការអនុវត្តច្បាប់ជាតិ និងដំណើរការបង្កើតគោលនយោបាយ។ សេចក្តីព្រាងផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ២០១៨-២០២២ បានដាក់បញ្ចូលយុទ្ធសាស្ត្រមួយដើម្បីឲ្យមានការចូលរួមកាន់តែច្រើនជាមួយនឹងគណៈកម្មាធិការនៃរដ្ឋសភា អំពីការអនុវត្តអនុសញ្ញា ស៊ី ដ។

៣. **ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា សូមលើកទឹកចិត្តដល់រដ្ឋាភិបាលក្នុងការពិចារណារៀបចំសន្និសីទថ្នាក់ជាតិស្តីពីការអនុវត្តអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស ក្រោយវដ្តការពិនិត្យជាសកលតាមកាលកំណត់(UPR) ជុំទីបី។ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ផ្តល់ការគាំទ្រ ក្នុងករណីដែលរដ្ឋាភិបាលសម្រេចរៀបចំសន្និសីទនេះ។**

**ការបង្កើតយន្តការបង្ការថ្នាក់ជាតិ (NPM) យោងតាមលក្ខខណ្ឌតម្រូវនៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម (OP-CAT) (118.13)**

៤. ក្នុងឆ្នាំ២០១៧ មានការចេញព្រះរាជក្រឹត្យមួយដែលចាត់ទុកជាមោឃៈទៅលើអនុក្រឹត្យស្តីពីការបង្កើតយន្តការបង្ការថ្នាក់ជាតិ ក្រោមពិធីសារអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម។ ចំណុចនេះ មានពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធយន្តការនេះឡើងវិញ។ ក្នុងខែមិថុនា ឆ្នាំ២០១៨ អនុគណៈកម្មាធិការបង្ការទារុណកម្ម បានដកយន្តការបង្ការថ្នាក់ជាតិនេះចេញបញ្ជីនៃមាត្រា១៧ គឺបញ្ជីយន្តការបង្ការថ្នាក់ជាតិដែលការអនុលោមតាមកាតព្វកិច្ចនៃមាត្រា១៧ មានការហួសពេលយូរពេក។[4]

៥. ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាលក្នុងការបន្តចាត់វិធានការនានា ជាពិសេសការផ្តល់មូលនិធិគ្រប់គ្រាន់ ដើម្បីធានាឲ្យមានឯករាជ្យភាពតាមផ្លូវការនិងក្នុងការប្រតិបត្តិការយន្តការបង្ការថ្នាក់ជាតិនេះ។

**ការអប់រំអំពីសិទ្ធិមនុស្សនិងសន្ធិសញ្ញានានា (118.42)**

៦. ពីឆ្នាំ២០១៤-២០១៦ យោងតាមគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិ ក្រសួងយុត្តិធម៌បានផ្តល់ការបណ្តុះបណ្តាលស្តីពីអនុសញ្ញាស៊ី ដ យេនឌ័រ និងច្បាប់ជាតិពាក់ព័ន្ធនានា ទៅដល់ចៅក្រមនិងព្រះរាជអាជ្ញា ក្រឡាបញ្ជីនិងមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ ចំនួន ៣៦៥០ នាក់ (ស្ត្រី ១២០៤ នាក់)។

៧. អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ក្នុងភាពជាដៃគូជាមួយអង្គការសហប្រជាជាតិ អង្គការ FHI 360 និងអង្គការខាណា(KHANA) បានរៀបចំសកម្មភាពបញ្ជ្រាបការយល់ដឹងដល់អ្នកធ្វើគោលនយោបាយនិងអាជ្ញាធរអនុវត្តច្បាប់ ស្តីពីការអនុវត្តច្បាប់និងគោលនយោបាយនានា ដោយរាប់ទាំង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរនិងអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព។ ការអនុវត្តច្បាប់និងគោលនយោបាយទាំងនេះ អាចបន្ទុចបង្អាក់ដល់ការទទួលបានសេវាកម្មសម្រាប់ប្រជាជនប្រឈមមុខខ្ពស់មួយចំនួន[5] នៅក្នុងករណីមួយចំនួន ជាពិសេស នៅពេលដែលមានការភ័យខ្លាចមានការចាប់ខ្លួន នាំឲ្យបុគ្គលទាំងនោះ ជៀសវាងក្នុងការមកទទួលសេវា ឬការចាប់ខ្លួនដាក់ស្តែងក្រោមច្បាប់ទាំងនេះ បានរំខានដល់ការទទួលបានសេវាកម្មទាំងនេះ។

៨. ក្រុមប្រឹក្សាជាតិជនពិការរបស់រដ្ឋាភិបាល បានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីតាមមូលដ្ឋានរបស់ខ្លួន ក្នុងខេត្តកោះកុង នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ។

**កំណែទម្រង់ច្បាប់ (118.27, 118.80, 118.91, 118.133)**

៩. អាទិភាពសំខាន់មួយក្នុងចំណោមអាទិភាពសំខាន់នានានៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រដ្ឋាភិបាល (២០១៣-២០១៨) គឺការពង្រឹងអភិបាលកិច្ចតាមរយៈ *"ការបន្តអនុវត្តការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ សុចរិតភាព តម្លាភាព និងគណនេយ្យភាព។"*[6]

១០. ការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ មានការរីកចម្រើនក្នុងវិស័យជាច្រើន ដូចជាការរៀបចំតុលាការ ការទទួលបានព័ត៌មាន យុត្តិធម៌អនីតិជន ជំនួយផ្នែកច្បាប់ និងការដាក់ទោសជំនួស។ ការប្រាស្រ័យទាក់ទងនៅក្នុងប្រព័ន្ធយុត្តិធម៌ និងថវិការដ្ឋាភិបាលសម្រាប់វិស័យយុត្តិធម៌ បានកើនឡើងនៅក្នុងរយៈប៉ុន្មានឆ្នាំថ្មីៗនេះ។[7]

១១. ក៏ប៉ុន្តែ ការធ្វើវិសោធនកម្មទៅលើច្បាប់ស្តីពីគណបក្សនយោបាយក្នុងឆ្នាំ២០១៧ បានធ្វើឲ្យមានការពន្យារពេលផ្នែករដ្ឋបាលរបស់គណបក្សនយោបាយមិនមានពេលកំណត់ ដោយគ្មានដំណើរការត្រឹមត្រូវ និងបានហាមឃាត់ដោយមិនមានពេលកំណត់ ទៅលើអ្នកដែលត្រូវបានផ្តន្ទាទោសសូម្បីតែពីបទល្មើសមជ្ឈិម ដែលចេញមកពីគណបក្សនយោបាយធំៗមួយចំនួន។[8] ក្នុងខែតុលា ឆ្នាំ២០១៧ រដ្ឋសភាបានអនុម័តវិសោធនកម្មច្បាប់មួយចំនួន ដែលអនុញ្ញាតិឲ្យមានការបែងចែកអាសនៈរបស់គណបក្សដែលត្រូវបានរំលាយ ឲ្យទៅគណបក្សដទៃទៀតនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។[9]

១២. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានលើកពីកង្វល់ថាការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដែលដាក់ជាបទល្មើសប្រមាថព្រះមហាក្សត្រ សកម្មភាពខុសច្បាប់ចំពោះការប្រមាថព្រះមហាក្សត្រ គឺមិនស្របទៅនឹងបទដ្ឋាន អន្តរជាតិស្តីពីសេរីភាពក្នុងការបញ្ចេញមតិឡើយ។[10] កង្វល់ស្រដៀងគ្នានេះដែរ ត្រូវបានលើកឡើងទាក់ទងនឹងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយរបស់គេហទំព័រនិងបណ្តាញផ្សព្វផ្សាយសង្គមតាមរយៈប្រព័ន្ធអ៊ីនធឺណែត។

១៣. ច្បាប់ស្តីពីសហជីព មានបទប្បញ្ញត្តិដែលមិនស្របទៅនឹងបទដ្ឋានអន្តរជាតិ ជាពិសេសស្តីពីការបង្កើត ការប្រព្រឹត្តិទៅ និងការរំលាយសហជីព។[11] ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៥ បានដាក់បញ្ចូលលក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជី ភារកិច្ចក្នុងការធ្វើរបាយការណ៍ដែលមានភាពស្មុគ្រស្មាញ និងលក្ខខណ្ឌតម្រូវអំពី "អព្យាក្រឹត្យភាពនយោបាយ" ហើយប្រសិនជាមិនបានបំពេញលក្ខខណ្ឌតម្រូវនេះទេ អាចនាំឲ្យមានការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ។[12]

**១៤. ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តរដ្ឋាភិបាលចាត់ឲ្យមានការពិគ្រោះយោបល់ដែលមានលក្ខណៈចូលរួមទូលំទូលាយ ជាមួយនឹងស្ថាប័នសាធារណៈនិងស្ថាប័នពាក់ព័ន្ធ នៅពេលណែនាំឲ្យប្រើប្រាស់ច្បាប់ថ្មីឬធ្វើវិសោធនកម្មច្បាប់ស្តីពីសិទ្ធិមនុស្ស និងបញ្ហាពាក់ព័ន្ធនានា ព្រមទាំងជំរុញឲ្យមានការពិនិត្យឡើងវិញទៅលើច្បាប់និងវិសោធនកម្មខាងលើ ដើម្បីជានាឲ្យមានភាពស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិ។**

**ឯករាជ្យភាពនៃតុលាការ និងការទទួលបានយុត្តិធម៌** (118.24, 118.79, 118.81-118.90, 118.94, 118.95)

១៥. ក្រសួងយុត្តិធម៌បន្តអនុវត្ត "ច្បាប់ជាមូលដ្ឋាន" ទាំងបី ស្តីពីប្រព័ន្ធយុត្តិធម៌ ដោយបានចេញអនុក្រឹត្យចំនួនបីទៅលើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបានបោះជំហានក្នុងការព្រាងច្បាប់ស្តីពីសារការី អាជ្ញាសាលា និងក្រឡាបញ្ជី។[13] ក្នុងឆ្នាំ២០១៦ ក្រសួងយុត្តិធម៌ បានចាត់វិធានការដ៏សំខាន់ក្នុងការតម្លើងប្រាក់បៀវត្សរ៍ របស់ចៅក្រមនិងព្រះរាជអាជ្ញា ក្នុងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ដើម្បីសម្រេចជោគជ័យក្នុងការងារនេះ ក្រសួងយុត្តិធម៌ បានអញ្ជើញអង្គភាពប្រឆាំងអំពើពុករលួយ ឲ្យតាមដានការប្រលងចូលរៀននៅរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។[14] ក៏ប៉ុន្តែ បញ្ហាប្រឈមជាលក្ខណៈរចនាសម្ព័ន្ធក្នុងការអនុវត្តច្បាប់និងស្ថាប័នយុត្តិធម៌ នៅតែបន្តមាន ដោយរួមទាំងនៅក្នុងវិស័យឯករាជភាពនិងការជានាផ្នែកនីតិវិធី មូលដ្ឋានភស្តុតាងទន់ខ្សោយ ក្នុងការផ្តន្ទាទោស និងនិរទណ្ឌភាពនៅតែបន្តកើតមាន។[15]

១៦. ថវិកាជំនួយផ្នែកច្បាប់បានកើនឡើងបីដងចន្លោះពីឆ្នាំ២០១៣ ដល់ ២០១៧ ដល់ចំនួន ១៥០.០០០ដុល្លារ ប៉ុន្តែ វានៅតែមិនគ្រប់គ្រាន់សម្រាប់ប្រទេសមួយដែលប្រជាជនស្ទើរពាក់កណ្តាល រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ឬនៅលើបន្ទាត់ភាពក្រីក្របន្តិចបន្តួចនោះ។ [16] ចាប់តាំងពីឆ្នាំ២០១២មក រដ្ឋាភិបាលបានបែងចែកផ្តល់ថវិកា ២០០លានរៀល (៥០.០០០ ដុល្លារអាមេរិក) ក្នុងមួយឆ្នាំ ដើម្បីគាំទ្រដល់ការទទួលបានសេវាផ្លូវច្បាប់សម្រាប់ស្ត្រីដែលជាជនរងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សា ហើយចំនួនស្ត្រីក្រីក្រដែលទទួលបានជំនួយផ្លូវច្បាប់ បានកើនឡើងពី១០៦ ក្នុងឆ្នាំ២០១៤ ដល់ ២៣៣ ក្នុងឆ្នាំ២០១៦។ ជំនួយផ្លូវច្បាប់ ដោយរួមបញ្ចូលទាំងការផ្តល់យោបល់ផ្លូវច្បាប់ អាចរកបានសម្រាប់ក្រុមប្រជាជនសំខាន់ៗ និងអ្នកស្រលាញ់ភេទដូចគ្នាក្នុងកម្រិតតិចតួច។ ការទទួលបានសេវានេះ នៅមានកម្រិតតិចតួច ដោយសារតែភាពស្មុគ្រស្មាញនៃដំណើរការ និងតម្រូវការក្នុងការបង្កើនទំនុកចិត្តសាធារណៈនៅក្នុងប្រព័ន្ធយុត្តិធម៌។

១៧. ក្នុងខែកក្កដា ឆ្នាំ២០១៦ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័ត។ ច្បាប់នេះចែងអំពីប្រព័ន្ធដាច់ដោយឡែកមួយ ដែលផ្តោតលើកម្មវិធីបង្វែរ ជាជាងការដាក់ទណ្ឌកម្ម។[17] ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌ បន្តធ្វើការលើការអនុវត្តច្បាប់នេះ។ មានការពន្យារពេលក្នុងការកំណត់ឲ្យច្បាស់អំពីអាយុរបស់យុវជនដែលត្រូវចាប់ខ្លួន ដើម្បីកំណត់ថាតើមានអាយុក្រោមអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌឬទេ ហើយជួនកាល អនីតិជននៅតែត្រូវបានគេឃុំខ្លួនជាមួយនីតិជន។ វិធានការនានា ដូចជា ការប្រើប្រាស់របាំងនិងសម្ភារៈសោតទស្សន៍សម្រាប់ការផ្តល់សក្ខីកម្មចល័ត គួរជួយការពារដល់សាក្សីជាកុមារនិងជនរងគ្រោះជាកុមារ។

**១៨. ដើម្បីលើកកម្ពស់ឯករាជភាពនៃតុលាការ កាត់បន្ថយអំពើពុករលួយឲ្យបានច្រើន និងលើកកម្ពស់ការទទួលបានយុត្តិធម៌ ស្របតាមកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ១៦ នោះ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា៖**

ក) លើកទឹកចិត្តដល់ក្រសួងយុត្តិធម៌ ឲ្យរៀបចំការសិក្សាអំពីសុចរិតភាពប្រព័ន្ធយុត្តិធម៌ ដូចមានចែងនៅក្នុងសូចនាករតាមដានរួម របស់ក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

ខ) ស្វាគមន៍ការអភិវឌ្ឍន៍ជាបន្តបន្ទាប់នៃគោលនយោបាយជាតិស្តីពីជំនួយផ្នែកច្បាប់ និងលើកទឹកចិត្តដល់ការអនុម័តឲ្យបានទាន់ពេលវេលា និងការផ្តល់ធនធានឲ្យបានគ្រប់គ្រាន់

គ) ស្វាគមន៍ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងលើកទឹកចិត្តដល់រដ្ឋាភិបាលក្នុងការអនុវត្តច្បាប់នេះ ដោយរួមទាំងតាមរយៈការធានាឲ្យមានការផ្តល់ធនធានឲ្យបានគ្រប់គ្រាន់។

**និទណ្ឌភាព** (118.13, 118.92, 118.105, 118.112-118.116)

១៩. និទណ្ឌភាពនៅតែបន្តជាបញ្ហាប្រឈមមួយ ជួនកាលបង្កើតជាលក្ខខណ្ឌសម្រាប់ដំណោះស្រាយស្របគ្នា ដូចជាការដោះស្រាយផ្នែកហិរញ្ញវត្ថុក្រៅប្រព័ន្ធតុលាការ ឬចំណាត់ការដោយហ្វូងមនុស្សក្រៅប្រព័ន្ធតុលាការ។ [18] និទណ្ឌភាពសម្រាប់ករណីដែលកើតឡើងដោយការទាមទារយុត្តិធម៌ដោយហ្វូងមនុស្ស នៅតែជាក្តីកង្វល់មួយដែរ គឺថា កម្រមានការស៊ើបអង្កេតណាស់ ហើយករណីទាំងនេះជាទូទៅត្រូវបានបិទចោល ដោយសារតែគេចាត់ទុកថាឧក្រិដ្ឋកម្មដែលបានកើតឡើងពីដំបូងនោះ ត្រូវបានដោះស្រាយរួចរាល់ហើយ។[19]

**២០. ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាលក្នុងការចាត់វិធានការដើម្បីដោះស្រាយបញ្ហានិទណ្ឌភាព ដោយរួមបញ្ចូលទាំងតាមរយៈការលើកកម្ពស់ការយល់ដឹងថា ទង្វើនានា ដូចជាអំពើហិង្សាបង្កដោយហ្វូងមនុស្ស ជាទង្វើមិនអាចទទួលយកបានទេ ហើយត្រូវមានការស៊ើបអង្កេតនិងកាត់ទោសចំពោះបទល្មើសទាំងនេះ។**

**សេរីភាពជាមូលដ្ឋាន** (118.104-118.111, 118.14-118.16, 118.18-118.20, 118.101, 118.102)

២១. សេរីភាពខាងសមាគម នៅបន្តជាបញ្ហាប្រឈម ជាពិសេស ចាប់តាំងពីការអនុម័តច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅឆ្នាំ២០១៥ និងច្បាប់ស្តីពីសហជីពក្នុងឆ្នាំ២០១៦មក។ ក្នុងឆ្នាំ២០១៧ រដ្ឋាភិបាលបានបញ្ជាឲ្យមានការបិទការិយាល័យវិទ្យាស្ថានជាតិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា ក្នុងបរិបទនៃការចោទប្រកាន់ថា សម្ភារៈបណ្តុះបណ្តាលរបស់វិទ្យាស្ថាននេះ បង្ហាញពីការចូលដៃជាមួយគណបក្សសង្គ្រោះជាតិ ដើម្បីធានានូវជ័យជំនះសម្រាប់ការបោះឆ្នោតឆ្នាំ២០១៨ និងបញ្ហានានាទាក់ទងនឹងការចុះបញ្ជីរបស់វិទ្យាស្ថាននោះ។ រដ្ឋាភិបាលបានពន្យារប្រតិបត្តិចំនួន៣០ថ្ងៃទៅលើអង្គការសមធម៌កម្ពុជា ដែលជាអង្គការមួយធ្វើការលើវិស័យសិទ្ធិដីធ្លី និងលុបឈ្មោះអង្គការបរិស្ថានមួយឈ្មោះ អង្គការមាតាធម្មជាតិ ចេញពីបញ្ជីអង្គការមិនមែនរដ្ឋាភិបាល ហើយបុគ្គលិកពីនាក់របស់អង្គការនេះ ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ពីបទទាក់ទងនឹងការប៉ុនប៉ងតាមរយៈវីដេអូបង្ហាញពីការសង្ស័យទៅលើសកម្មភាពបូមខ្សាច់ដោយខុសច្បាប់។ ការណែនាំផ្នែករដ្ឋបាលដែលបានដាក់ចេញ

ដោយក្រសួងមហាផ្ទៃ កាលពីខែតុលា ឆ្នាំ២០១៧ តម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាល ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានចំនួនបីថ្ងៃមុនធ្វើសកម្មភាព សូម្បីតែការជូនដំណឹងបែបនេះ មិនបានតម្រូវឲ្យមាននៅក្នុងច្បាប់ក៏ដោយ។[20]

២២. រដ្ឋាភិបាលបានលុបចោលអាជ្ញាប័ណ្ណរបស់ស្ថានីយ៍វិទ្យុឯករាជ្យមួយចំនួន ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានបិទចោល ហើយអ្នកការសារព័ត៌មានឯករាជ្យចំនួនពីរនាក់ត្រូវបានចោទប្រកាន់តែបទ "ចារកម្ម"។[21] មានការងារជាច្រើនដែលត្រូវធ្វើ ទាក់ទងនឹងការការពារអ្នកកាសែត ដែលរាយការណ៍បញ្ហារសើបនានាទាក់ទងនឹងបរិស្ថានធនធានធម្មជាតិ និងអំពើពុករលួយ ជាពិសេស ការរាយការណ៍បែបស៊ើបអង្កេត។[22]

២៣. ការហាមឃាត់ការធ្វើបាតុកម្មទ្រង់ទ្រាយធំ កាលពីខែមករា ឆ្នាំ២០១៤ ជាការផ្លាស់ប្ដូរវិធីសាស្ត្រដែលជាទូទៅមានការសណ្ដោសប្រណីចំពោះការធ្វើបាតុកម្មនានា។[23] ក្នុងឆ្នាំ២០១៦ បាតុកម្មរបស់អង្គការសង្គមស៊ីវិលដែលអំពាវនាវឲ្យមានការដោះលែងបុគ្គលិករបស់អង្គការអាដហុក និងអគ្គលេខាធិការរងគណៈកម្មាធិការរៀបចំការបោះឆ្នោត (ដែលគេហៅថាការប្រមូលផ្ដុំ ថ្ងៃច័ន្ទពណ៌ខ្មៅ) ត្រូវបានបំបែកដោយបង្ខំ។[24] នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ការដង្ហែក្បួនដោយសន្តិវិធីដើម្បីរំលឹកទិវាលំនៅដ្ឋានពិភពលោក ត្រូវបានបង្ក្រាបដោយហិង្សា។ [25] មានការរាយការណ៍អំពីវត្តមាននគរបាល កាន់តែច្រើនឡើង រួមទាំងនគរបាលមិនបង្ហាញអត្តសញ្ញាណ នៅមុន និងក្នុងពេលធ្វើសកម្មភាពឬព្រឹត្តិការណ៍សាធារណៈរបស់អង្គការមិនមែនរដ្ឋាភិបាល។[26]

២៤. ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា រំលេចឡើងអំពីសារៈសំខាន់នៃ សម្លេង ភាពច្នៃប្រឌិត និងភាពប៉ិនប្រសប់របស់សង្គមស៊ីវិល ក្នុងការសម្រេចតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយរួមទាំងនៅពេលដែលសម្លេងទាំងនោះ មានលក្ខណៈរិះគន់ក៏ដោយ។ នៅក្នុងបរិបទនេះ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ៖

ក) លើកទឹកចិត្តដល់រដ្ឋាភិបាលក្នុងការអនុញ្ញាតិឲ្យមានការបញ្ចេញមតិនិងការរៀបចំសមាគមឲ្យបានទូលាយ លើកលែងតែត្រូវបានកំហិតដែលមានការអនុញ្ញាតិក្រោមកាតិកាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ

ខ) ជៀសវាងការកាត់ទោសអ្នកកាសែត អ្នកការពារសិទ្ធិ និងតួអង្គសង្គមស៊ីវិលនានា ដើម្បីជៀសវាងការបង្អាក់ពួកគេមិនឲ្យបញ្ចេញទស្សនៈដោយសេរី និង

គ) គោរពសេរីភាពជួបជុំ ដោយរួមទាំង អនុលោមជាមួយនឹងការណែនាំអនុវត្តសម្រាប់ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។

កំណែទម្រង់ការបោះឆ្នោត និងការចូលរួមក្នុងជីវភាពនយោបាយ (118.23, 118.117-118.123)

២៥. ក្នុងឆ្នាំ២០១៤ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានកែទម្រង់ ដើម្បីឲ្យមានចំនួនតំណាងស្មើគ្នារវាងគណបក្សកាន់អំណាចនិងគណបក្សប្រឆាំង និងសមាជិកឯករាជ្យមួយរូប។[27] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចាប់ផ្តើមរៀបចំសម្រាប់ការបោះឆ្នោតឃុំសង្កាត់លើកទីបួនដែលបានប្រព្រឹត្តិទៅនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧។ បញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មីមួយ ដែលបានបង្កើតឡើងនៅចុងឆ្នាំ២០១៦ ត្រូវបានអ្នកឃ្លាំមើល ចាត់ទុកថាមានសុក្រឹត្យភាពជាង៩៨%។ ប្រជាជនកម្ពុជា បានចេញទៅបោះឆ្នោតក្នុងអាត្រាមួយខ្ពស់ខ្លាំង ហើយការបោះឆ្នោតបានប្រព្រឹត្តិទៅដោយសន្តិវិធី និងមានបណ្តឹងតិចតួច។[28] ការបោះឆ្នោត បង្ហាញថាបានរៀបចំឡើងដោយយោងតាមច្បាប់។[29]

២៦. វិធានការតុលាការដែលបានចាត់ឡើងប្រឆាំងនឹងមេដឹកនាំពីរនាក់របស់អតីតគណបក្សនយោបាយប្រឆាំង (គណបក្សសង្គ្រោះជាតិ) ដោយចោទប្រកាន់ទាក់ទងនឹងការក្បត់ជាតិទៅលើលោក កឹម សុខា និងបទញុះញង់ និងបរិហារកេរ្តិ៍ទៅលើលោក សម រង្ស៊ី ក្នុងខែកញ្ញា ឆ្នាំ២០១៧។ លោក កឹម សុខា នៅបន្តជាប់ពន្ធនាគារ តាំងពីពេលនោះមក។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ តុលាការកំពូល បានបញ្ជាឲ្យរំលាយគណបក្សសង្គ្រោះជាតិ និងបានហាមឃាត់សមាជិកជាន់ខ្ពស់ចំនួន១១៨រូប ដោយរួមទាំងសមាជិកសភាទាំងអស់ មិនឲ្យធ្វើនយោបាយសម្រាប់រយៈពេល៥ឆ្នាំ។[30] ការរំលាយគណបក្សសង្គ្រោះជាតិ បានអនុញ្ញាតិឲ្យមានការបែងចែកអាសនៈទាំងនោះនៅរដ្ឋសភាដោយមិនមានការបោះឆ្នោតថ្មី និងឃុំទាំងអស់ដែលពីមុន នៅក្រោមការកាន់កាប់របស់គណបក្សសង្គ្រោះជាតិ ឲ្យទៅគណបក្សប្រជាជនកម្ពុជា។[31]

**២៧. ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាលក្នុងការធានាឲ្យមានដំណើរការនយោបាយដែលមានលក្ខណៈបរិយាប័ន្ននិងមានលក្ខណៈចូលរួម ដែលពលរដ្ឋគ្រប់រូបអាចចូលរួមក្នុងកិច្ចការសាធារណៈ ដោយផ្ទាល់ឬតាមរយៈតំណាងដែលពលរដ្ឋអាចជ្រើសរើសបានដោយសេរី តាមរបៀបដែលមានការធានានិងមានការគោរពដល់បញ្ចេញមតិដោយសេរីអំពីឆន្ទៈរបស់ម្ចាស់ឆ្នោតនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ស្របតាមមាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងជាមធ្យោបាយដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦។**

**អ.វ.ត.ក** (118.97-118.99)

២៨. សំណុំរឿង 002/01 នៅ អ.វ.ត.ក បានបញ្ចប់នៅចុងឆ្នាំ២០១៦។ សំណុំរឿង 002/02 បានបញ្ចប់ក្នុងឆ្នាំ២០១៧ ដោយរំពឹងថានឹងត្រូវប្រកាសសាលក្រមក្នុងឆ្នាំ២០១៨។ សំណុំរឿង ០០៣ បានឈានដល់ដំណាក់កាលដាក់សារណាជាចុងក្រោយរបស់សហព្រះរាជអាជ្ញា ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ និងសំណុំរឿង០០៤ ត្រូវបានបំបែកជាសំណុំរឿងដាច់ដោយឡែកចំនួនបី។

**ការឃុំខ្លួន និងលក្ខខណ្ឌក្នុងពន្ធនាគារ** (118.60, 118.61, 118.96)

២៩. "យុទ្ធនាការដែលមានរយៈពេលប្រាំមួយខែ ដើម្បីបង្ក្រាបគ្រឿងញៀនខុសច្បាប់" ដែលបានចាប់ផ្តើមប្រតិបត្តិការក្នុងខែមករា ឆ្នាំ២០១៧ និងបន្តប្រតិបត្តិការក្នុងខែមិថុនា ឆ្នាំ២០១៧ បាននាំឲ្យមានការកើនឡើងយ៉ាងខ្លាំងនៃចំនួនអ្នកជាប់ក្នុងពន្ធនាគារ។ ប្រការនេះបានដាក់គំនាបបន្ថែមទៀតទៅលើកន្លែងឃុំឃាំង និងបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើលក្ខខណ្ឌរស់នៅនិងសុខភាពរបស់អ្នកជាប់ក្នុងពន្ធនាគារ ក៏ដូចជាប៉ះពាល់ដល់បរិយាកាសការងាររបស់បុគ្គលិកពន្ធនាគារ។ ចំនួនមនុស្សដែលត្រូវបានឃុំខ្លួនដោយមិនមានដីកាដែលអាចយកទៅអនុវត្តបាន នៅតែមានកម្រិតខ្ពស់ ដោយក្នុងនោះ មានអ្នកជាប់ពន្ធនាគារចំនួនតែ២៥%ប៉ុណ្ណោះដែលកំពុងទទួលទោសចុងក្រោយរបស់ពួកគេ គិតត្រឹមខែធ្នូ ឆ្នាំ២០១៧។[32] នេះជាក្តីកង្វល់មួយអំពីការរាលដាលនៃការឃុំខ្លួនបណ្តោះអាសន្ន។[33]

៣០. **ដើម្បីបង្ការកុំឲ្យមានការប្រព្រឹត្តិមិនគប្បី និងដើម្បីឲ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា សូមផ្តល់អនុសាសន៍ថា រដ្ឋាភិបាលគួរចាត់វិធានការដើម្បីកាត់បន្ថយភាពចង្អៀតណែនក្នុងកន្លែងឃុំឃាំង ដោយរាប់ទាំងតាមរយៈការពិនិត្យទៅលើជម្រើសផ្សេងទៀតក្រៅពីការដាក់ឃុំ និងដើម្បីកាត់បន្ថយចំនួនមនុស្សដែលនៅជាប់ឃុំបណ្តោះអាសន្ន តាមរយៈការណែនាំឲ្យមាននីតិវិធីតុលាការកាន់តែឆាប់រហ័ស ហើយត្រូវធានាថា ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវប្រើសម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ។**

**ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ** (118.128, 118.134, 118.136, 118.138, 118.139, 118.141-118.145, 118.158)

៣១. ក្នុងឆ្នាំ២០១៦ ប្រទេសកម្ពុជាបានឆ្លងផុតពីឋានៈជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ [34] កំណើនសេដ្ឋកិច្ចបានបន្តនៅកម្រិតខ្ពស់ស្មើរតែចំនួន៧% ហើយភាពក្រីក្របានបន្តថយចុះ ក៏ប៉ុន្តែ ប្រជាជនស្មើរមួយភាគបី កំពុងតែរស់នៅជិតបន្ទាត់ភាពក្រីក្រ និងស្ថិតក្នុងហានិភ័យដែលអាចរអិលធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ។ [35] ផលប្រយោជន៍ដែលបានទទួលមកពីការអភិវឌ្ឍន៍ មិនទាន់ទទួលបានស្មើគ្នានៅគ្រប់វិស័យនៃសង្គមនៅឡើយទេ ហើយបញ្ហាប្រឈមធំៗនានា នៅតែបន្តកើតមាន ដោយរួមមានទាំង វិសមភាពប្រាក់ចំណូលការបែងចែករវាងទីក្រុង/ជនបទ និងភាពងាយរងគ្រោះដោយសារតែការការប៉ះទង្គិចតូចតាច (minor shocks) ជាដើម។[36] ការដោះស្រាយបញ្ហាកាត់បន្ថយភាពក្រីក្រ និងកំណើនដែលមានលក្ខណៈបរិយាប័ន្ន ត្រូវបានរដ្ឋាភិបាលកំណត់រកឃើញនៅក្នុងឆ្នាំ២០១៧ ថាជាបញ្ហាប្រឈមកាត់ទទឹងក្នុងពេលអនាគត។[37]

៣២. រដ្ឋាភិបាលបានស្វែងរកការពង្រីកការទទួលបានហិរញ្ញវត្ថុ ជាពិសេសក្នុងតំបន់ជនបទ។ សេវាកម្មហិរញ្ញវត្ថុដែលបានទៅដល់តំបន់ជនបទច្រើនច្រើនបំផុតនោះ គឺតាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុ ដោយក្នុងនោះ មានស្ថាប័នមី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៦៨ បានចុះបញ្ជីជាមួយធនាគារជាតិ ហើយមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនកំពុងផ្តល់ឥណទាននិងកម្ចី។ ក្នុងឆ្នាំ២០១៧ ស្ថាប័នទាំងនេះបានផ្តល់ប្រាក់កម្ចីជាង ៣,៩៩៣ពាន់លានដុល្លាអាមេរិក ដែលជាចំនួនកើនឡើងពី ២,០៣៣ពាន់លានដុល្លា ក្នុងឆ្នាំ២០១៤ និង ២,៩៥៣ពាន់លានក្នុងឆ្នាំ២០១៥។ បើយោងតាមសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានោះ កម្ចីប្រហែល៧០%បានផ្តល់ឲ្យទៅស្ត្រី ដែលពេលបច្ចុប្បន្ននេះ ស្ត្រីទទួលបានសេវាហិរញ្ញវត្ថុពីស្ថាប័នពាណិជ្ជកម្មនិងស្ថាប័នមីក្រូហិរញ្ញវត្ថុ ច្រើនដូចបុរសដែរ។ ក្រសួងអភិវឌ្ឍន៍ជនបទ បានពង្រីកគម្រោងឥណទានខ្នាតតូចដោយមានអាត្រាការប្រាក់ទាប ដើម្បីជំរុញឲ្យប្រជាជននៅតាមជនបទ ជាពិសេសស្ត្រី ទទួលបានកម្ចីសម្រាប់អាជីវកម្មខ្នាតតូចនិងសកម្មភាពកសិកម្ម។ ក្នុងឆ្នាំ២០១៧ គម្រោងឥណទាននេះ បានបញ្ចេញដើមទុនសរុប ១,៣១លានដុល្លារ ទៅដល់អតិថិជនចំនួន ៦០៣៥នាក់ (៤៩៨៩ នាក់ជាស្ត្រី ឬ ៨២,៧% ជាស្ត្រី) នៅក្នុងខេត្តចំនួន១៥។

៣៣. ក្រសួងអភិវឌ្ឍន៍ជនបទ បានធ្វើឲ្យមានការរីកចម្រើនសំខាន់ៗ ក្នុងការលើកកម្ពស់ក្នុងការទទួលបានទឹកស្អាតកាន់តែប្រសើរនិងអនាម័យនៅតំបន់ជនបទ ស្របតាមគោលដៅនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។ ភាគរយនៃប្រជាជនតាមជនបទដែលទទួលបានការផ្គត់ផ្គង់ទឹកស្អាតកាន់តែប្រសើរ បានកើនឡើងពី៤២% ក្នុងឆ្នាំ២០០៩ ទៅ ៤៤,៣% ក្នុងឆ្នាំ២០១៣ និងដល់៥៣% ក្នុងឆ្នាំ២០១៥។ ជាងនេះទៀត ការទទួលបានអនាម័យកាន់តែប្រសើរ បានឈានដល់៥៦% ក្នុងឆ្នាំ២០១៥ គឺកើនពី ៣៧,៥% ក្នុងឆ្នាំ២០១៣ និង២៥% ក្នុងឆ្នាំ២០១០។ ប្រការនេះ តំណាងឲ្យការរួមចំណែកដ៏សំខាន់របស់រដ្ឋាភិបាលចំពោះការកែលម្អសុខភាពនិងអាហារូបត្ថម្ភក្នុងចំណោមពលរដ្ឋរស់នៅតំបន់ជនបទ។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យឆ្នាំ២០១៤-២០២៥ ត្រូវបានអនុម័តក្នុងខែមករា ឆ្នាំ២០១៤។

**ការទទួលខុសត្រូវរបស់ធុរកិច្ច ការងារ (118.125-118.127)**

៣៤. សហគ្រាសធុរកិច្ច បន្តមានតួនាទីយ៉ាងសំខាន់មួយនៅក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ដែលអាចប៉ះពាល់ដល់ការទទួលបាននូវសិទ្ធិមនុស្ស ដូចជាសិទ្ធិដីធ្លីនិងសិទ្ធិលំនៅដ្ឋាន សិទ្ធិនៅកន្លែងការងារ សមភាពយេនឌ័រ ក្នុងចំណោមសិទ្ធិផ្សេងៗទៀត។ នេះជាការរំលេចឡើងអំពីតួនាទីរបស់រដ្ឋាភិបាលក្នុងការការពារសិទ្ធិមនុស្ស។ ក្នុងឆ្នាំ២០១៧ រដ្ឋាភិបាលបានដាក់ចេញនូវការគាំពារសង្គមដែលបានកែលម្អមួយសម្រាប់កម្មករ បានដាក់ចេញនូវគម្រោងផ្តល់ការចំណាយសម្រាប់កម្មករមានផ្ទៃពោះ និងបង្កើនប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករក្នុងវិស័យឧស្សាហកម្មវាយនភណ្ឌនិងស្បែកជើង ក្នុងអាត្រា១១% ក្នុងឆ្នាំ២០១៨។ រដ្ឋាភិបាល បានពន្យារដំណើរការទៅលើសេចក្តីព្រាងច្បាប់ចម្រូងចម្រាស់មួយស្តីពីការដោះស្រាយវិវាទការងារ។[38] ទោះបីជាមានកិច្ចប្រឹងប្រែងទាំងអស់នេះហើយក៏ដោយក្តី ក៏លក្ខខណ្ឌរស់នៅរបស់ប្រជាជនដែលកំពុងធ្វើការនៅក្នុងរោងចក្រ ជាពិសេសស្ត្រី នៅតែមានភាពក្រីក្រ និងប្រាក់ខែសរុបនៅមានកម្រិតទាបនៅឡើយ។ ការធ្វើទុក្ខទោសខាងផ្លូវភេទនៅកន្លែងធ្វើការនៅបន្តជាបញ្ហាធ្ងន់ធ្ងរមួយដែលបានធ្វើឲ្យចុះខ្សោយដល់សិទ្ធិនានារបស់ស្ត្រី និងការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច។

៣៥. អង្គការសហប្រជាជាតិ កំពុងធ្វើការជាមួយរដ្ឋាភិបាលនិងសហគ្រាសធុរកិច្ច ក្នុងការផ្តល់ដំណោះស្រាយគ្រប់គ្រាន់សម្រាប់ករណីរំលោភបំពានសិទ្ធិដីធ្លីនិងសិទ្ធិលំនៅដ្ឋាន ដោយរួមមានទាំងតាមរយៈការគាំទ្រការប្រជុំ "តុសន្តិភាព" រវាងសហគមន៍រុនតាឯកក្នុងខេត្តសៀមរាបនិងអាជ្ញាធរអប្សរា។[39] អង្គការសហប្រជាជាតិ តាមរយៈការិយាល័យតំបន់ប្រចាំនៅទីក្រុងបាងកក កំពុងផ្តល់ការគាំទ្រសម្រាប់រដ្ឋាភិបាលនិងសហគ្រាសធុរកិច្ចក្នុងការលើកកម្ពស់ធុរកិច្ចនិងសិទ្ធិមនុស្សក្នុងបរិបទនៃរបៀបវារៈឆ្នាំ២០៣០។

**៣៦. ក្នុងបរិបទនៃការធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ១៧ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា សូមលើកទឹកចិត្ត៖**

**ក) រដ្ឋាភិបាលក្នុងការលើកកម្ពស់ការអនុវត្តរបស់ធុរកិច្ចប្រកបដោយការទទួលខុសត្រូវ និងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋនិងឯកជនឲ្យមានប្រសិទ្ធភាព តាមរយៈការបង្កើតឲ្យមានផែនការសកម្មភាពជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ផ្អែកតាមគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងមានការពិគ្រោះយោបល់ជាមួយវិស័យឯកជន សង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត**

**ខ) សហការបន្ថែមទៀតរវាងរដ្ឋាភិបាលនិងវិស័យឯកជន ក្នុងការតាក់តែងច្បាប់និងគោលនយោបាយ ដែលកំណត់ឲ្យបានច្បាស់អំពី "ការយាយីផ្លូវភេទ" ព្រមទាំងបង្ការនិងដាក់ទណ្ឌកម្មឲ្យមានប្រសិទ្ធភាពទៅលើការយាយីផ្លូវភេទ នៅកន្លែងធ្វើការ។**

**សិទ្ធិដីធ្លីនិងសិទ្ធិលំនៅដ្ឋាន** (118.129-118.135)

៣៧. ប្រទេសកម្ពុជាជួបប្រទះបទពិសោធន៍នៃការកាប់ព្រៃឈើនិងធ្លាក់ចុះព្រៃឈើយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែបុព្វហេតុមួយចំនួនដែលបានរកឃើញ រួមមាន ការប្តូរឲ្យទៅជាដីសម្រាប់ធ្វើកសិកម្មពាណិជ្ជកម្ម ការជីករ៉ែ សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច ការតាំងទីលំនៅនិងការធ្វើដីកសិកម្មដោយស្របច្បាប់ច្បាប់និងមិនស្របច្បាប់ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងវារីអគ្គិសនីទ្រង់ទ្រាយធំ ការកសាងផ្លូវការកាប់ឈើស្របច្បាប់និងខុសច្បាប់ ការប្រមូលផលឈើសម្រាប់ដុត ព្រមទាំងភ្លើងឆេះព្រៃ។[40]

៣៨. អភិបាលកិច្ចព្រៃឈើនិងការអនុវត្តច្បាប់ភូមិបាលដែលមានសភាពទន់ខ្សោយ រួមជាមួយនឹងការខ្វះខាតការចុះបញ្ជីដីរដ្ឋនិងការកំណត់ព្រំសីមាដីព្រៃ បានជះឥទ្ធិពលទៅលើធនធានព្រៃ។[41] ជាលទ្ធផល ប្រការនេះនាំឲ្យមានវិវាទទាក់ទងនឹងព្រៃ ដែលជារឿយៗ មានកើតឡើងដោយសារតែបញ្ហានៃអំណាចមិនស្មើគ្នា បញ្ហាផលប្រយោជន៍ផ្សេងគ្នាទៅលើដីព្រៃនិងផលិតផលព្រៃឈើ បញ្ហាអភិបាលកិច្ចនិងសិទ្ធិមនុស្ស។[42]

៣៩. រដ្ឋាភិបាលបានធ្វើឲ្យមានការរីកចម្រើនក្នុងការផ្តល់កម្មសិទ្ធិដីធ្លីនិងការដោះស្រាយវិវាទមួយចំនួន។ ចាប់តាំងពីការចាប់កកើតកម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីរហូតមកដល់ចុងឆ្នាំ២០១៧ បណ្ណកម្មសិទ្ធិដីធ្លីចំនួន ៤.៨៨១.៥៨២ ត្រូវ

បានផ្តល់ជូនប្រជាពលរដ្ឋ ដែលស្មើនឹង៦៦.៤% នៃកម្មសិទ្ធិដែលប៉ាន់ប្រមាណចំនួន៧លាន ដែលត្រូវផ្តល់ជូនឲ្យបានត្រឹមឆ្នាំ២០៣០។ យន្តការបណ្តោះអាសន្នជាច្រើនក្នុងការដោះស្រាយបញ្ហាដីធ្លីដែលនៅសល់ ត្រូវបានបង្កើតឡើង ទោះបីជាវិវាទសកម្មមួយចំនួននៅតែមានបន្តមានភាពមិនច្បាស់លាស់ក៏ដោយ។

៤០. ខណៈដែលលទ្ធភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសហគមន៍ ជាការវិវត្តន៍វិជ្ជមានមួយនៅក្នុងតំបន់នោះ ដំណើរការទទួលបណ្ណកម្មសិទ្ធិដីសមូហភាព មានសភាពស្មុគស្មាញ ប្រើរយៈពេលយូរ និងត្រូវចំណាយច្រើន។[43] គិតត្រឹមខែមិថុនា ឆ្នាំ២០១៨ ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចចំនួន៤៥៥ ក្នុងប្រទេសកម្ពុជា មានតែសហគមន៍ចំនួន១៤១ប៉ុណ្ណោះដែលត្រូវបានក្រសួងអភិវឌ្ឍន៍ជនបទទទួលស្គាល់ជាសហគមន៍ជនជាតិដើមភាគតិច ១២៨ ត្រូវបានចុះបញ្ជីតាមផ្លូវច្បាប់នៅក្រសួងមហាផ្ទៃ ហើយមានតែ២៤ប៉ុណ្ណោះដែលបានទទួលបណ្ណកម្មសិទ្ធិដីសមូហភាព។

៤១. ក្នុងឆ្នាំ២០១៥ រដ្ឋាភិបាលបានដាក់ចេញ "ឯកសារស"ស្តីពីគោលនយោបាយដីធ្លី ជាការឆ្លើយតបទៅនឹងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចនិងកំណែទម្រង់ដីធ្លី ដើម្បីគាំទ្រដល់ជីវភាពរបស់ប្រជាជន។ ក្នុង "ឯកសារស" នោះ (ចំណុច ៥ និង ៧) មានបញ្ចូល សេចក្តីណែនាំ និងសកម្មភាពដើម្បីសម្រេចបាននូវសមភាពយេនឌ័រក្នុងវិស័យដីធ្លីនិងការចុះបញ្ជីដីធ្លី។

**៤២. ក្នុងបរិបទដើម្បីសម្រេចបាននូវសិទ្ធិដីធ្លីនិងលំនៅដ្ឋាន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ១០ និង ១៥ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តរដ្ឋាភិបាល៖**

**ក) អនុម័តវិធីសាស្ត្រនិងយន្តការដែលមានតម្លាភាពនិងមានសង្គតិភាព សម្រាប់តាមដាននិងដោះស្រាយបញ្ហាដីធ្លី ដោយរួមមានទាំង តម្រូវការអប្បបរមាដើម្បីឲ្យមានយុត្តិធម៌សម្រាប់ការកំណត់អំពីសំណង**

**ខ) ពិនិត្យឡើងវិញនិងធ្វើឲ្យសាមញ្ញនូវដំណើរការសម្រាប់ស្នើសុំការចុះបញ្ជីដីសហគមន៍ និងដើម្បីបង្កើនថវិកាសម្រាប់ការផ្តល់កម្មសិទ្ធិដីសហគមន៍ ក្នុងគោលបំណងដើម្បីពន្លឿននីតិវិធីដំណើរការការទាមទារចុះបញ្ជី។**

**សុខភាព រួមទាំងមេរោគអេដស៍** (118.147-118.157, 118.160, 118.171)

៤៣. កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលសុខភាពសំខាន់ៗមួយចំនួន ដូចជាការធ្លាក់ចុះយ៉ាងខ្លាំងនៃអាត្រាមរណភាពកុមារ និងការសម្រេចបានឆាប់នៃគោលដៅអភិវឌ្ឍន៍សហសវត្សដែលទាក់ទងនឹងវិស័យនេះ។ ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសចំនួនដប់ដែលអនុវត្តបានលឿនក្នុងភាពជាដៃគូសម្រាប់សុខភាពមាតា ទារក និងកុមារ។ ក៏ប៉ុន្តែ លទ្ធផលក្នុងវិស័យសុខភាពនេះមានភាពផ្សេងៗគ្នា ដោយយោងតាមស្ថានភាពសង្គមសេដ្ឋកិច្ចនិងទីតាំង។ ឧទាហរណ៍ កុមារដែលស្ថិតនៅក្នុង

ក្រុមក្រុមស្ថិតិ២០%នៃកុមារក្រីក្របំផុតនោះ ពួកគេស្ថិតក្នុងហានិភ័យដែលអាចប៉ះពាល់ដល់ជីវិតរបស់ពួកគេមុនឈានដល់អាយុ៥ឆ្នាំ ក្នុងអាត្រាខ្ពស់ជាងបីដង បើប្រៀបធៀបនឹងក្រុមកុមារ២០%នៃក្រុមកុមារដែលមានបំផុតនោះ។[44]

៤៤. មូលនិធិសមធម៌សុខភាពស្វែងរកឲ្យមានការទទួលបានសេវាថែទាំសុខភាពដោយមិនបង់កម្រៃ សម្រាប់គ្រួសារក្រីក្របំផុត រួមទាំងកូនរបស់ខ្លួនដែរ។[45] ផែនការយុទ្ធសាស្ត្រសុខភាពលើកទីបី ២០១៦-២០២០ របស់ក្រសួងសុខាភិបាល ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការធ្វើឲ្យមានការរីកចម្រើនកាន់តែច្រើនឡើងសំដៅឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសាកល។ គោលដៅគោលនយោបាយដ៏ទូលំទូលាយនៃផែនការយុទ្ធសាស្ត្រសុខភាពលើកទីបី គឺលទ្ធផលសុខភាពប្រជាជនកាន់តែប្រសើរ តាមរយៈការបង្កើនការការពារហានិភ័យទាក់ទងនឹងហិរញ្ញវត្ថុ នៅក្នុងការទទួលបានសេវាថែទាំសុខភាពដែលមានគុណភាព។ ការចំណាយលុយផ្ទាល់ខ្លួនរបស់អ្នកជម្ងឺ នៅតែមានកម្រិតខ្ពស់ក្នុងអាត្រា៥៨% នៃការចំណាយសម្រាប់សុខភាពសរុបក្នុងឆ្នាំ២០១៥។[46]

៤៥. ការឆ្លើយតបរបស់ប្រទេសកម្ពុជាចំពោះមេរោគអេដស៍ក្នុងរយៈពេលពីរទសវត្សនេះ មានភាពជោគជ័យយ៉ាងខ្លាំង និងជាលទ្ធផលមានការធ្លាក់ចុះអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនពេញវ័យទូទៅដែលមានអាយុចន្លោះពី ១៥-៤៩ឆ្នាំ មកនៅត្រឹម០,៦% ក្នុងឆ្នាំ២០១៦។ ចំណុចនេះបានធ្វើឲ្យប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន៧ នៅទូទាំងសាកលលោកដែលសម្រេចបានគោលដៅ ៩០-៩០-៩០ (ដែលមានន័យថា អ្នកផ្ទុកមេរោគអេដស៍ចំនួន៧៣% មានកម្រិតបន្ទុកមេរោគអេដស៍ក្នុងឈាមទាបបំផុត) នៅក្នុងឆ្នាំ២០១៧។ ចំនួនករណីឆ្លងថ្មីនៃមេរោគអេដស៍ បានធ្លាក់ចុះមកនៅត្រឹមតែប៉ុន្មានរយនាក់តែប៉ុណ្ណោះក្នុងមួយឆ្នាំ ហើយចំនួនអ្នកផ្ទុកមេរោគអេដស៍សរុបក្នុងប្រទេសកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមានប្រហែល ៧០.០០០នាក់ ប៉ុណ្ណោះ។ ការរីករាលដាល បានប៉ះពាល់ដល់ស្ត្រីនិងបុរសស្មើរដូចគ្នានៅក្នុងប្រទេសកម្ពុជា។ អ្នកផ្ទុកមេរោគអេដស៍ចំនួន ៥៨.៥១៦នាក់ កំពុងទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ដោយមិនគិតថ្លៃនៅក្នុងប្រទេសកម្ពុជា គិតត្រឹមចុងខែធ្នូ ឆ្នាំ២០១៧។ កម្មវិធីមេរោគអេដស៍ប្រកបដោយភាពជោគជ័យរបស់ប្រទេសកម្ពុជា កើតចេញមកពីគោលនយោបាយនិងក្របខណ្ឌយុទ្ធសាស្ត្រដែលមានភាពល្អប្រសើរ។

៤៦. ក្រសួងសុខាភិបាល បានអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន ២០០៨-២០១៥ ដែលផ្តល់នូវការថែទាំងដល់ស្ត្រីមានផ្ទៃពោះគ្រប់រូប ដោយមានរួមទាំងការធ្វើតេស្តិ៍លើការខ្វះឈាមក្រហម មេរោគអេដស៍ និងជម្ងឺកាមរោគ។ ក្នុងឆ្នាំ២០១៧ ស្ត្រីមានផ្ទៃពោះ៨៤% ស្ម័គ្រចិត្តធ្វើតេស្តិ៍រកមេរោគអេដស៍ ដែលកើនពីចំនួន១៥% ក្នុងឆ្នាំ២០០៨។ ភាគរយនៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ កំពុងទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ដើម្បីបង្ការការចម្លងពីម្តាយទៅកូន បានកើនឡើងពី២៧% ក្នុងឆ្នាំ២០០៨ ទៅដល់ ៨១,២% ក្នុងឆ្នាំ២០១៧។

៤៧. ប្រជាជនដែលរស់នៅ ធ្វើការ ឬពឹងផ្អែកទៅលើផ្លូវ មានភាពងាយរងគ្រោះជាពិសេសដោយសារការរំលោភបំពាន និងដោយសារការបោសសម្អាតនិងបញ្ជូនទៅមណ្ឌលនានា ដូចជាមណ្ឌលសង្គមកិច្ចនៅភ្នំពេញ (ព្រៃស្ពឺ) ជាដើម។ មនុស្សទាំងនេះមួយចំនួន មានពិការភាពខាងផ្នែកចិត្តសង្គម និងមានបញ្ហាសុខភាព ដោយរួមមានទាំងមេរោគ/ជម្ងឺអេដស៍និងការញៀនថ្នាំ ហើយត្រូវការការគាំទ្រផ្នែកវេជ្ជសាស្ត្រដែលមានវិជ្ជាជីវៈត្រឹមត្រូវ ហើយដែលមិនអាចរកបាននាពេលបច្ចុប្បន្ននេះ។ ក្នុងឆ្នាំ២០១៥ រដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិល បានចូលរួមក្នុងសន្និសីទថ្នាក់ជាតិស្តីពីស្ថានភាពអ្នករស់នៅតាមផ្លូវ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ និងរៀបចំអនុសាសន៍នានា។

៤៨. យុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទនិងបន្តពូជ ត្រូវបានដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១៧ ដើម្បីធានាថាសេវាកម្មសុខភាពផ្លូវភេទនិងបន្តពូជទូលំទូលាយ អាចរកបាននៅគ្រប់កម្រិតនៃការផ្តល់សេវាកម្ម។ ខណៈដែលអាត្រាបង្កកំណើតទាំងមូលក្នុងប្រទេសកម្ពុជាក្នុងចំណោមស្ត្រីអាយុពី១៥-៤៩ឆ្នាំ មានការធ្លាក់ចុះក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះ អាត្រាក្នុងចំណោមស្ត្រីនិងក្មេងស្រីអាយុពី១៥ ដល់១៩ឆ្នាំ បានកើនឡើងពី ៤៧ ក្នុងចំណោម ១០០០ ក្នុងឆ្នាំ២០០៥ ទៅដល់ ៥៧នាក់ ក្នុងឆ្នាំ២០១៤។ អាត្រាបង្កកំណើតនៅក្នុងតំបន់ជនបទសម្រាប់ក្មេងស្រីជំទង់ មានចំនួនបីដងច្រើនជានៅតំបន់ទីក្រុង។[47] ក្នុងចំណោមក្មេងស្រីជំទង់នៅក្នុងដែលមានដៃគូអាយុពី១៥-១៩ឆ្នាំនោះ ស្ទើរតែ៧១% មិនមានប្រើប្រាស់វិធីពន្យារកំណើតណាមួយនោះទេ។[48]

៤៩. ដោយសារតែការសម្រេចបានជាបន្តបន្ទាប់នៃសិទ្ធិទទួលបានសុខភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ៣ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាល៖

ក) ពង្រីកការគាំពារសុខភាពសង្គម និងយន្តការបង់ថ្លៃមុន ព្រមទាំងបង្កើនការផ្តល់មូលនិធិក្នុងស្រុកទៅដល់វិស័យសុខាភិបាល ក្នុងគោលបំណងដើម្បីកាត់បន្ថយបន្ទុកផ្នែកសុខភាពទៅលើគ្រួសារ ដើម្បីកាត់បន្ថយការចំណាយលុយផ្ទាល់ខ្លួនច្រើនទៅលើការថែទាំសុខភាព និងដើម្បីសម្រេចឲ្យបានជាបន្តបន្ទាប់នៃសិទ្ធិទទួលបានសុខភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ ៣

ខ) បង្កើនការវិនិយោគហិរញ្ញវត្ថុក្នុងស្រុក ដោយរាប់ទាំងការសហការជាមួយវិស័យឯកជន ក្នុងការផ្តល់អន្តរាគមន៍ប្រកបដោយចីរភាពដែលមានលក្ខណៈច្នៃប្រឌិតថ្មីៗ ផ្តោតលើមនុស្ស និងផ្អែកលើភស្តុតាងសម្រាប់កម្មវិធីបង្ការ ព្យាបាល ថែទាំ និងគាំទ្រផ្នែកមេរោគអេដស៍ ក្នុងគោលបំណងដើម្បីឈានសម្រេចបានគោលដៅជាតិក្នុងការបញ្ចប់ការរីករាលដាលជម្ងឺអេដស៍ ដែលជាការគំរាមកំហែងដល់សុខភាពសាធារណៈ ឲ្យបានត្រឹមឆ្នាំ២០២៥

គ) អនុវត្តអនុសាសន៍ពីសន្និសីទជាតិឆ្នាំ២០១៥ស្តីពីស្ថានភាពអ្នករស់នៅតាមផ្លូវ ហើយ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា សូមបញ្ជាក់សារជាថ្មីអំពីការគាំទ្ររបស់ខ្លួនក្នុងដំណាក់កាលអនុ

វត្តអនុសាសន៍ទាំងនោះ។

**អប់រំ** (118.140, 118.159. 118.162-118.168)

៥០. មានការរីកចម្រើនក្នុងការកាត់បន្ថយការលួចចម្លងដែលមានសភាពរាលដាលនៅក្នុងពេលប្រលង តាមរយៈភាពជាអ្នកដឹកនាំនយោបាយនិងគោលនយោបាយដ៏រឹងមាំចេញពីក្រសួងអប់រំ និងតាមរយៈការជំរុញឲ្យគ្រូបង្រៀនទទួលបានប្រាក់ខែសមរម្យ ដែលកើនឡើងជិតបីដងក្នុងរយៈពេលបីឆ្នាំ។[49] កំណែទម្រង់ទាំងនេះ ក៏បានជួយទប់ស្កាត់ "ការចំណាយបន្ថែម" ក្រៅផ្លូវការ ពីគ្រួសារដើម្បីបញ្ជូនកូនទៅរៀន និងជួយជ្រោមជ្រែងដល់ការកសាងសាលារៀនបន្ថែមទៀត។ ការបណ្តុះបណ្តាលគ្រូកំពុងបម្រើការ ក៏កំពុងត្រូវបានពិនិត្យឡើងវិញ ដើម្បីធានាឲ្យបាននូវស្តង់ដាបង្រៀនប្រកបដោយគុណភាព។ ប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត ក៏កំពុងត្រូវបានរៀបចំ ក៏ដូចជាវិថីអាជីពដែលត្រូវបានធ្វើការកែប្រែសម្រាប់គ្រូបង្រៀននិងនាយកសាលា។ ការអប់រំទាក់ទងនឹងផ្លូវភេទទូលំទូលាយមួយ កំពុងត្រូវបានបញ្ចូលទៅក្នុងការអប់រំសុខភាពសម្រាប់ថ្នាក់ទី៥ ដល់១២។

៥១. ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការដើម្បីធានាឲ្យមានការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាជិតដល់កម្រិតសាកលក្នុងប្រទេស។[50] ក៏ប៉ុន្តែ អាត្រាបោះបង់ការសិក្សាថ្នាក់មធ្យមសិក្សា មានកម្រិតខ្ពស់។[51] ភាពខុសគ្នារវាងយេនឌ័រ នៅតែបន្តកើតមាននៅកម្រិតមធ្យមសិក្សា ដែលជារឿយៗកើតចេញមកពីអសន្តិសុខស្បៀងនិងភាពក្រីក្រ ហើយកាន់តែមានភាពខុសគ្នាខ្លាំងនៅកម្រិតឧត្តមសិក្សា។ នៅក្នុងការវិភាគអំពីនិន្នាការតាមវិស័យថ្មីៗនេះ វាបានបង្ហាញច្បាស់ថា មានក្មេងស្រីបានបញ្ចប់ការសិក្សាច្រើនជាងក្មេងប្រុសនៅកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ[52] ហើយសម្រាប់ឧត្តមសិក្សា ខណៈដែលមានភាពស្មើគ្នានៃយេនឌ័រក្នុងកម្រិតបរិញ្ញាប័ត្ររងនិងបរិញ្ញាប័ត្រនោះ មានស្ត្រីចំនួនតិចជាងបុរសឆ្ងាយណាស់ដែលបន្តការសិក្សាថ្នាក់ក្រោយបរិញ្ញាប័ត្រ។ ឧទាហរណ៍ និស្សិតស្ត្រីចំនួនតែ២២% ប៉ុណ្ណោះ ដែលបានបន្តការសិក្សាកម្មវិធីកម្រិតបរិញ្ញាប័ត្រជាន់ខ្ពស់នៅក្នុងឆ្នាំ២០១៦-២០១៧។[53] ក្មេងស្រីមកពីគ្រួសារដែលទទួលរងប៉ះពាល់ដោយសារមេរោគអេដស៍ ច្រើនតែខកខានមិនបានទៅរៀន បើប្រៀបធៀបនឹងក្មេងស្រីមកពីគ្រួសារដែលមិនទទួលរងប៉ះពាល់ដោយមេរោគអេដស៍។

៥២. ក្នុងឆ្នាំ២០១៦ រដ្ឋាភិបាលបានដាក់ចេញនូវផែនការសកម្មភាពអប់រំពហុភាសា ដើម្បីកែលម្អការទទួលបានការអប់រំសម្រាប់កុមារជនជាតិដើមភាគតិច។ [54] នាពេលបច្ចុប្បន្ននេះ ក្រសួងអប់រំយុវជននិងកីឡាកំពុងរៀបចំផែនការសកម្មភាពពហុភាសាថ្មីមួយសម្រាប់ឆ្នាំ២០១៩-២០២៣ ដែលនឹងជាមគ្គុទេសក៏សម្រាប់ធ្វើឲ្យមានការរីកចម្រើននៅក្នុងវិស័យនេះ ក្នុងរយៈពេល៥ឆ្នាំខាងមុខ។

**៥៣. ក្នុងបរិបទនៃការធានាឲ្យមានសិទ្ធិទទួលបានការអប់រំ និងសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅទី ៤ និងទី ១០ *ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា* លើកទឹកចិត្តដល់រដ្ឋាភិបាលក្នុ**

**ងការខិតខំប្រឹងប្រែងឲ្យបានកាន់តែខ្លាំងថែមទៀត ដើម្បីដោះស្រាយបញ្ហានៃការបោះបង់ការសិក្សា ដើម្បីជួយក្មេងប្រុសឲ្យបានបញ្ចប់ការអប់រំបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ព្រមទាំងដើម្បីកែលម្អការទទួលបានការអប់រំថ្នាក់មធ្យមសិក្សា និងថ្នាក់ឧត្តមសិក្សា សម្រាប់ក្មេងស្រី ដោយរួមទាំងតាមរយៈការវិភាគអំពីឫសគល់បញ្ហា ដូចជាគុណភាពអប់រំ ការចំណាយរបស់គ្រួសារសម្រាប់ការអប់រំ អនាគតការងារ និងកម្រិតនៃការបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលអាចរកបាន។**

**បណ្ដាញសុវត្ថិភាព (118.146, 118.149)**

៥៤. រដ្ឋាភិបាលបានអនុម័តក្របខណ្ឌគោលនយោបាយថ្នាក់ជាតិគាំពារសង្គម (២០១៦-២០២៥) ដែលជាផែនទីបង្ហាញផ្លូវរយៈពេលវែងមួយ ផ្តោតទៅលើជំនួយសង្គមនិងសន្តិសុខសង្គម។ [55] គោលដៅចម្បងនៃក្របខណ្ឌគោលនយោបាយនេះ គឺធ្វើការបន្សុី ប្រមូលផ្តុំ និងពង្រឹងកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាពនៃប្រព័ន្ធគាំពារសង្គម។ ក្របខណ្ឌគោលនយោបាយនេះ ក៏ស្វែងរកការពង្រីកការគ្របដណ្ដប់ទៅលើបណ្ដាញសុវត្ថិភាពសង្គមសម្រាប់ពលរដ្ឋទាំងអស់។ ក៏ប៉ុន្តែ គម្លាតដែលមាននៅចន្លោះរវាងគោលនយោបាយនិងការអនុវត្ត ដែលស្តែងចេញតាមរយៈការដែលក្រុមងាយរងគ្រោះទទួលបានរបបគាំពារសង្គមនេះក្នុងកម្រិតមួយតិចតួចនៅឡើយ។

**៥៥. ក្នុងបរិបទនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ១ និងលេខ១០ និងសិទ្ធិទទួលបានសន្តិសុខសង្គម ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាល ធានានូវសមត្ថភាពស្ថាប័ន និងបែងចែកផ្តល់ធនធានឲ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ដើម្បីជាការជួយជ្រោមជ្រែងដល់ក្របខណ្ឌគោលនយោបាយថ្នាក់ជាតិគាំពារសង្គម (២០១៦-២០២៥) នេះ**

**កុមារ (118.55, 118.64, 118.65, 118.73, 118.74, 118.171), អំពើហិង្សាលើកុមារ (118.26, 118.62), ពលកម្មកុមារ (118.26, 118.67-118.71, 118.72, 118.125)**

៥៦. រដ្ឋាភិបាលបានបិទទីតាំងថែទាំស្នាក់នៅមួយចំនួនដែលដែលមានការរំលោភបំពាន ដាពិសេស "មណ្ឌលកុមារកំព្រា" និងស្វែងរកការធ្វើប្បញ្ញត្តិគ្រប់គ្រងការសុំកូនឆ្លងប្រទេស។ ក្រសួងសង្គមកិច្ច អតីយុវជន និងយុវនីតិសម្បទា បានប្រកាសឲ្យប្រើប្រាស់ផែនការសកម្មភាពមួយក្នុងឆ្នាំ២០១៧ សម្រាប់ការកែលម្អការថែទាំកុមារ ដោយមានគោលដៅ ធ្វើយ៉ាងណាឲ្យកុមារ៣០% បានវិលត្រឡប់ដោយសុវត្ថិភាពទៅកាន់ក្រុមគ្រួសាររបស់ពួកគេវិញ បន្ទាប់ពីការថែទាំនៅមណ្ឌលចំនួន២ឆ្នាំរួចមក។ រដ្ឋាភិបាល កំពុងធ្វើការក្នុងការពង្រឹងការអនុវត្តច្បាប់សុំកូន ដើម្បីធានាថា មានការការពារមុនពេលអនុវត្តឲ្យមានការសុំកូន។

៥៧. ក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលបានប្រកាសដាក់ឲ្យប្រើប្រាស់ផែនការសកម្មភាពទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (២០១៧-២០២១) ក្នុងឆ្នាំ២០១៧។

៥៨. ពលកម្មកុមារគឺជាក្តីបារម្ភមួយ ហើយបើយោងតាមអង្គការសហប្រជាជាតិ មានកុមារកម្ពុជាអាយុពី៥ដល់១៧ឆ្នាំ ចំនួន១៩% កំពុងមានភាពសកម្មក្នុងវិស័យសេដ្ឋកិច្ច។[56] ការរីកចម្រើនទាក់ទងនឹងការទទួលបានសូចនាករ និងគោលដៅស្តីពីពលកម្មកុមារ នៅមានកម្រិតទាបនៅឡើយ។

**៥៩. នៅក្នុងបរិបទដើម្បីសម្រេចបានតាមស្តង់ដារពលកម្មអន្តរជាតិ សិទ្ធិកុមារ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ៨ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាល៖**

**ក) វិនិយោគក្នុងការផ្តល់ការងារដល់បុគ្គលិកសង្គមកិច្ចនៅក្នុងស្រុកចំនួន១៦៥ និងឃុំចំនួន១៦៤៦ ដើម្បីផ្តល់សេវាទប់ស្កាត់និងការឆ្លើយតបចំពោះកុមារដែលងាយរងគ្រោះដោយសារអំពើហិង្សា និងដែលទទួលរងអំពើហិង្សា**

**ខ) ផ្តល់ធនធានឲ្យបានគ្រប់គ្រាន់ដើម្បីពង្រឹងការអនុវត្តច្បាប់ទាក់ទងនឹងពលកម្មកុមារ និងដើម្បីធានាថាការធ្វើអធិការកិច្ចការងារត្រូវបានរៀបចំឡើងពាសពេញផ្ទៃប្រទេស ជាពិសេស ក្នុងវិស័យក្រៅផ្លូវនិងនៅតំបន់ជនបទទាំងឡាយ។**

**ស្ត្រី (118.49-118.56, 118.64), អំពើហិង្សាលើស្ត្រី (118.62, 118.65, 118.72, 118.124)**

៦០. ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី២ ដែលគ្របដណ្តប់ឆ្នាំ២០១៤-២០១៨ ផ្តោតលើការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាយេនឌ័រ។ សេចក្តីណែនាំថ្នាក់ជាតិសម្រាប់គ្រប់គ្រងអំពើហិង្សាលើស្ត្រីនិងកុមារក្នុងវិស័យសុខាភិបាល ត្រូវបានអនុម័តក្នុងឆ្នាំ២០១៥ និងបន្ទាប់មក មានការបោះពុម្ពផ្សាយសៀវភៅវេជ្ជសាស្ត្រសម្រាប់អ្នកផ្តល់សេវាថែទាំ។ ក្រុមការងារបច្ចេកទេសយេនឌ័រទទួលបន្ទុកអំពើហិង្សាយេនឌ័រ (TWGG-GBV) ត្រូវបានបង្កើតឡើងដើម្បីពង្រឹងការសម្របសម្រួលនិងគាំទ្រដល់កិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី តាមរយៈផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី២។[57] សេចក្តីព្រាងស្តីពី *ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារី-យុទ្ធសាស្ត្រដើម្បីអនុវត្តអាទិភាពនៃការទប់ស្កាត់* ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៧។ ផ្នែកមួយទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ត្រូវបានបញ្ចូលដោយជោគជ័យទៅក្នុងការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាក្នុងឆ្នាំ២០១៤ ដើម្បីប្រមូលព័ត៌មានអំពីអាត្រានៃការរីករាលដាលនៃអំពើហិង្សាលើស្ត្រី។ បញ្ហាប្រឈមនៅតែបន្តមាន ជាពិសេសការផ្តល់ធនធានតិចតួចពេក សម្រាប់យន្តការស្ត្រីថ្នាក់ជាតិ គឺក្រសួងកិច្ចការនារីនិងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា គាំទ្រដល់ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការពង្រីកការធ្វើផែនការថវិកាឆ្លើយតបនឹងតម្រូវការយេនឌ័រ ក្នុងក្រសួងនានា។

៦១. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការពារជនរងគ្រោះ (២០០៥) បានបណ្តាលឲ្យមានការចេញដីកាការពារតិចតួចបំផុតសម្រាប់ជនរងគ្រោះ និងខ្វះការកាត់ទោសជនល្មើស។ ករណីដូចជាការរំលោភសេពសន្ថវៈនិងអំពើហិង្សាក្នុងគ្រួសារ ជារឿយៗ ត្រូវបានដោះស្រាយតាមរយៈប្រព័ន្ធយុត្តិធម៌ក្រៅផ្លូវការ។ ខណៈដែលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ អនុញ្ញាតិឲ្យមានការសម្រុះសម្រួលតែនៅក្នុងករណីមិនមែនព្រហ្មទណ្ឌក៏ដោយ ក៏គេច្រើនតែអនុវត្តការសម្រុះសម្រួលនេះ ដោយនៅក្នុងករណីជាច្រើន ធ្វើឲ្យជនរងគ្រោះវិលត្រឡប់ទៅរស់នៅជាមួយជនល្មើសដែលមិនត្រូវបានស៊ើបអង្កេតព្រហ្មទណ្ឌវិញ។ ការដែលមន្ត្រីអនុវត្តច្បាប់និងមន្ត្រីតុលាការ ខ្វះការយល់ដឹងអំពីយេនឌ័រ នៅពេលដោះស្រាយជាមួយជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទនិងបទល្មើសផ្លូវភេទ បានបណ្តាលឲ្យមានវប្បធម៌ស្ងៀមស្ងាត់ ហើយមានករណីតិចតួចណាស់ដែលបានទៅដល់តុលាការ។[58]

៦២. ផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រ ជាពិសស នៅក្នុងគ្រួសារ និងនៅក្នុងសាលារៀន សហគមន៍ កន្លែងការងារ និងប្រព័ន្ធផ្សព្វផ្សាយ នៅតែបន្តកើតមានជាធម្មតានៅក្នុងប្រទេសកម្ពុជា។ ប្រពៃណីក្នុងច្បាប់ស្រី ដែលរៀបរាប់អំពីរបៀបដែលក្មេងស្រីនិងស្ត្រីគួរប្រតិបត្តិ បានរឹតត្បឹតស្ត្រីក្នុងការប្រើប្រាស់សិទ្ធិស្មើភាពគ្នា បានដាក់កំហិតទៅលើជម្រើសនានា និងបានជះឥទ្ធិពលទៅលើការសម្រេចចិត្ត។[59]

៦៣. ទោះបីមានការកែលម្អមួយចំនួនទៅលើការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេវាពលរដ្ឋ នយោបាយ និងការសម្រេចចិត្តក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះក៏ដោយ ក៏ស្ត្រីនៅបន្តមានតំណាងតិចតួចបំផុត។

**៦៤. ក្នុងបរិបទដើម្បីសម្រេចបាននូវសមភាពយេនឌ័រនិងសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ៥ និងលេខ១៦ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាលៈ**

**ក) ពិនិត្យឡើងវិញទៅលើច្បាប់និងគោលនយោបាយនានាដើម្បីធានាថា ការសម្រុះសម្រួលក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ត្រូវអនុវត្តបានតែក្នុងករណីសមស្របប៉ុណ្ណោះ និងកែលម្អការទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើហិង្សា ដោយរួមមានទាំងការជំនះឧបសគ្គនានា ដូចជាក្រឹត្យក្រមយេនឌ័រ ដើម្បីទទួលបានយុត្តិធម៌នៅដំណាក់កាលនគរបាលនិងតុលាការ**

**ខ) លុបបំបាត់ផ្នត់គំនិតខុសឆ្គងទាក់ទឹងនឹងយេនឌ័រតាមលក្ខណៈប្រពៃណី និងបង្កើតយុទ្ធសាស្ត្រទូលំទូលាយមួយ ដើម្បីកែសម្រួលនិងលុបបំបាត់ឥរិយាបថតាមទម្រង់បិតាធិបតេយ្យ និងផ្នត់គំនិតខុសឆ្គងដែលរើសអើងទៅលើស្ត្រី ដោយរួមមានទាំងច្បាប់ស្រីផង**

**គ) ចាត់វិធានការ ដោយរួមទាំងតាមរយៈឲ្យមានការចូលរួមពីគណបក្សនយោបាយនានា ដើម្បីដោះស្រាយបញ្ហានៃការមានតំណាងស្ត្រីតិចតួចជាលក្ខណៈប្រព័ន្ធ ក្នុងតួនាទីធ្វើការសម្រេចចិត្ត និងអនុម័តយន្តការ**

ដែលមានចងកាតព្វកិច្ច ដើម្បីបង្កើនការចូលរួមរបស់ស្ត្រី ដូចជាប្រព័ន្ធកូតាដែលគាំទ្រដល់យេនឌ័រដែលមានតំណាងតិចតួច។

## ការរើសអើងដោយសារមូលហេតុនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ

៦៥. ការគាំទ្រថ្មីៗពីមន្ត្រីរដ្ឋាភិបាលមួយចំនួន ទៅដល់អ្នកស្រលាញ់ភេទដូចគ្នា ត្រូវបានស្វាគមន៍។

៦៦. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសាររបស់ប្រទេសកម្ពុជា (១៩៨៩) កំណត់ថា ការរៀបអាពាហ៍ពិពាហ៍ គឺជាកិច្ចព្រមព្រៀងឬកិច្ចសន្យារវាងបុរសម្នាក់និងស្ត្រីម្នាក់ (មាត្រា៣)។ មាត្រា១២នៃច្បាប់ស្តីពីការងារក្នុងប្រទេសកម្ពុជា (១៩៩៧) ចែងអំពីភាពស្មើគ្នានៅកន្លែងការងារ ទោះបីជាមិនជាមិនបានចែងច្បាស់អំពីការហាមឃាត់ការរើសអើងដោយសារមូលហេតុនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រក៏ដោយ។ គេត្រូវការកំណែទម្រង់ច្បាប់និងគោលនយោបាយ ដើម្បីដោះស្រាយបញ្ហានៃការរើសអើងទៅលើអ្នកស្រលាញ់ភេទដូចគ្នា នៅក្នុងគ្រួសារ នៅក្នុងសហគមន៍ និងនៅកន្លែងការងារ។

៦៧. ការធ្វើបាបទៅលើអ្នកស្រលាញ់ភេទដូចគ្នានៅតាមសាលារៀនបង្កឡើងដោយមិត្តភក្តិនិងគ្រូបង្រៀន នៅតែបន្តជាបញ្ហានៅឡើយ។ ក្រសួងអប់រំយុវជននិងកីឡា បានទទួលស្គាល់បញ្ហានេះ និងចាប់ផ្តើមដាក់បញ្ចូលបញ្ហានិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ទៅក្នុងកម្មវិធីសិក្សាតាមសាលារៀន (ជាផ្នែកមួយនៃបំណិនជីវិតនិងការអប់រំទាក់ទងនឹងផ្លូវភេទទូលំទូលាយ) ហើយគ្រូបង្រៀននឹងត្រូវរំញោចឲ្យមានការយល់ដឹង តាមរយៈការបណ្តុះបណ្តាលអំពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។

**៦៨. នៅក្នុងបរិបទនៃការលើកកម្ពស់សមភាពនិងដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ១០ និង១៦ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តរដ្ឋាភិបាល**

**ក) ពិចារណាក្នុងការធ្វើវិសោធនកម្មច្បាប់ និងកែប្រែការអនុវត្តដែលអនុញ្ញាតិឲ្យមានការរៀបអាពាហ៍ពិពាហ៍អ្នកស្រលាញ់ភេទដូចគ្នា និងការទទួលស្គាល់តាមផ្លូវច្បាប់ទៅលើអ្នកប្តូរយេនឌ័រ ដើម្បីអនុញ្ញាតិឲ្យមានការផ្លាស់ប្តូរភេទ នៅក្នុងឯកសារអត្តសញ្ញាណកម្ម**

**ខ) លើកកម្ពស់គោលនយោបាយសម្រាប់ការអប់រំដែលមិនរើសអើងដែលមានការដាក់បញ្ចូលនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ដោយរួមបញ្ចូលទាំងការបង្រៀនអំពីបញ្ហានានាទាក់ទងនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ និងលើកកម្ពស់អំពីវិធីដើម្បីដោះស្រាយការយល់ឃើញអវិជ្ជមានជុំវិញបញ្ហាទាក់ទងនឹងផ្លូវភេទ។**

ក្រុមជនភាគតិច/ក្រុមសាសនាភាគតិច (118.58, 118/59)

៦៩. ផែនការយុទ្ធសាស្រ្តអត្តសញ្ញាណកម្មជាតិរបស់រដ្ឋាភិបាល (២០១៧-២០២៦) ស្វែងរកការធានាថា មនុស្សគ្រប់រូបត្រូវបានទទួលស្គាល់នៅចំពោះមុខច្បាប់។ ថ្មីៗនេះ ក្រុមជនភាគតិចវៀតណាមនិងខ្មែរក្រោម ជួបការប្រឈមក្នុងការទទួលបានការចុះបញ្ជីកំណើតនិងអត្តសញ្ញាណប័ណ្ណ។[60]

៧០. ក្នុងឆ្នាំ២០១៦ រដ្ឋាភិបាលបានប្រកាសដាក់ឲ្យប្រើប្រាស់ផែនការសកម្មភាពជាតិអប់រំពហុភាសា ដើម្បីកែលម្អការទទួលបានការអប់រំសម្រាប់កុមារមកពីក្រុមជនជាតិដើមភាគតិច។[61] នាពេលបច្ចុប្បន្ននេះ ក្រសួងអប់រំយុវជននិងកីឡា កំពុងរៀបចំផែនការសកម្មភាពពហុភាសាថ្មីមួយសម្រាប់ឆ្នាំ២០១៩ ដល់ ២០២៣ ដែលនឹងជាមគ្គុទេសក៍សម្រាប់ដឹកនាំឲ្យមានការរីកចម្រើនក្នុងវិស័យនេះ សម្រាប់រយៈពេល៥ឆ្នាំទៅមុខទៀត។

**៧១. ដើម្បីធានាគ្មាននរណាម្នាក់ត្រូវបានទុកចោលនៅក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសគោលដៅទី១០នោះ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តរដ្ឋាភិបាល៖**

**ក) ពន្លឿនដំណើរការចុះបញ្ជីជនជាតិវៀតណាមនិងខ្មែរក្រោមទាំងអស់នៅក្នុងប្រទេសកម្ពុជា ជាពិសេសកុមារ និងធានាថាពួកគេទទួលបានសិទ្ធិសេដ្ឋកិច្ចនិងសង្គមកិច្ច**

**ខ) ប្រមូលទិន្នន័យអំពីក្រុមជនជាតិដើមភាគតិច ក្រុមជនភាគតិច និងក្រុមសាសនាភាគតិច ដោយរួមបញ្ចូលទាំងជំរឿនដែលនឹងត្រូវធ្វើក្នុងពេលខាងមុខ ដោយគោរពតាមគោលការណ៍បែងចែកទិន្នន័យតាមប្រភេទ ការកំណត់ស្វ័យអត្តសញ្ញាណ តម្លាភាព ឯកជនភាព ការចូលរួម និងគណនេយ្យភាព។[62]**

**គ) អនុវត្តឲ្យបានគ្រប់កន្លែងនូវផែនការសកម្មភាពជាតិសម្រាប់ការអប់រំពហុភាសា (២០១៩-២០២៣) និងធានាឲ្យមានការផ្តល់មូលនិធិគ្រប់គ្រាន់។**

**ជនពិការ** (118.25, 118.137, 118.169, 118.170)

៧២. ជនពិការជួបប្រទះឧបសគ្គនានានៅក្នុងសង្គម និងក្នុងការចូលទៅទទួលសេវាសាធារណៈនិងការទទួលបានការងារ។ ការិយាល័យបោះឆ្នោត មិនបង្កលក្ខណៈងាយស្រួលផ្នែករាងកាយ ជាលក្ខណៈប្រព័ន្ធនៅឡើយទេ។[63] សេចក្តីណែនាំលម្អិតអំពីការបង្កលក្ខណៈងាយស្រួលថ្នាក់ជាតិមួយ ត្រូវបានព្រាងឡើង ហើយកម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ជនពិការក្រីក្រ កំពុងត្រូវបានអនុវត្ត។ ក៏ប៉ុន្តែ ការវិនិយោគសាធារណៈក្នុងកម្រិតទាប និងកង្វះខាតភស្តុតាង (ទិន្នន័យ) ដើម្បីជាព័ត៌មានសម្រាប់គោលនយោបាយនិងកម្មវិធីនានា គឺជាកត្តាប្រឈម។ ក្រឹត្យក្រមសង្គម បន្តដើរតួនាទីយ៉ាងសំខាន់ ជាឧបសគ្គដល់ការចូលរួម។

៧៣. មានការគាំទ្រលក្ខណៈវិជ្ជាជីវៈតិចតួចណាស់ដែលអាចរកបាននៅក្នុងប្រទេស សម្រាប់អ្នកមានពិការភាពខាងផ្លូវចិត្តសង្គមនិងបញ្ញាស្មារតី។[64] ក៏ប៉ុន្តែ សេចក្តីថ្លែងជាសាធារណៈស្តីពីបរិយាប័ន្ន ដែលបានថ្លែងដោយមន្ត្រីរដ្ឋាភិ

បាល គឺជាសញ្ញាវិជ្ជមាន។ ផែនការយុទ្ធសាស្ត្របច្ចុប្បន្ន មានរួមបញ្ចូលគោលបំណងក្នុងការផ្តល់ការទទួលបានសេវាសុខភាពស្មើភាពគ្នា។[65]

៧៤. ក្នុងបរិបទនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ១៧ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តរដ្ឋាភិបាលឲ្យរៀបចំវិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យចំនួនជនពិការក្នុងប្រទេសកម្ពុជា ប្រភេទពិការភាព សេវាកម្មដែលពួកគេត្រូវការ ក៏ដូចជាឧបសគ្គចម្បងៗដែលពួកគេប្រឈមក្នុងការទទួលបានសិទ្ធិរបស់ពួកគេនិងក្នុងការចូលរួមដោយសេរីនៅក្នុងសង្គម។

**ការជួញដូរមនុស្ស** (118.75-118.78)

៧៥. រដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការបង្ក្រាបបទល្មើស ដូចជាការជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រីនិងកុមារ ទោះបីជាត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក៏ដោយ។[66] ការលើកកម្ពស់ការទប់ស្កាត់ គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រនានាក្នុងផែនការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ២០១៤-២០១៨ ព្រមទាំងសកម្មភាពទប់ស្កាត់សំខាន់ៗ រួមមានទាំង កិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ បានកើតមានឡើង។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន និងអង្គការអភិវឌ្ឍន៍នានា[67] ដែលរំលេចឡើងនូវសារៈសំខាន់នៃការទប់ស្កាត់ ការការពារជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងការកាត់ទោសជនល្មើស។ គណៈកម្មាធិការជាតិនិងដៃគូដែលជាអង្គការមិនមែនរដ្ឋាភិបាល បានផ្សព្វផ្សាយតាមវិទ្យុ ឃុតខ្លីតាមទូរទស្សន៍ និងកម្មវិធីផ្សាយផ្ទាល់ ការជជែកពិភាក្សាស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សនិងការលើកកម្ពស់ចំណាកស្រុកប្រកបដោយសុវត្ថិភាព ខណៈដែលក្រសួងអប់រំយុវជននិងកីឡា បានបញ្ជ្រាបសារអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្សនៅក្នុងបណ្តាញយុវជន។

*៧៦. គោលនយោបាយចំណាកស្រុកដើម្បីការងារសម្រាប់ប្រទេសកម្ពុជា ២០១៥-២០១៨* បានដាក់ចេញនូវក្របខណ្ឌសម្រាប់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពទៅលើការចំណាកស្រុកដើម្បីការងារ ការពង្រឹងភាពអង់អាចនិងការការពារសិទ្ធិរបស់កម្មករចំណាកស្រុកទាំងបុរសនិងស្ត្រី ព្រមទាំងការលើកកម្ពស់អំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកទៅលើការអភិវឌ្ឍន៍។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងរៀបចំបង្កើតគោលការណ៍ណែនាំសម្រាប់ការកំណត់អត្តសញ្ញាណនិងការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបានបង្កើតប្រព័ន្ធព័ត៌មានចំណាកស្រុកដើម្បីការងារ ដោយមានការគាំទ្រពីអង្គការដៃគូ ដើម្បីប្រមូលទិន្នន័យដែលមានការបែងចែកតាមភេទនិងតាមវិស័យ ស្តីពីចំនួនកម្មករកម្ពុជាដែលបានធ្វើចំណាកស្រុកតាមរយៈយន្តការធម្មតា។

៧៧. ក្នុងបរិបទដើម្បីសម្រេចឲ្យបានបទដ្ឋានពលកម្មអន្តរជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ៨ ក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា លើកទឹកចិត្តដល់រដ្ឋាភិបាលក្នុងការបង្កើនយន្តការការពារសម្រាប់អ្នកចំណាកស្រុកកម្ពុជាទៅធ្វើការនៅក្រៅប្រទេស ដោយរាប់បញ្ចូលទាំង កម្មករធ្វើការតាមផ្ទះ និងតាមដានឲ្យបានជិតដល់ទៅលើទីភ្នាក់ងាររកការងារ ដែលបានជ្រើសរើសនិងត្រៀមបម្រុងកម្មករចំណាកស្រុកកម្ពុជាឲ្យទៅធ្វើការនៅបរទេស។

---

[1] The Cambodia UN Country Team consists of UNRC, FAO, IAEA, IFAD, UN, IOM, UN, UNCDF, UN, UNEP, UNESCO, UN, UN-HABITAT, UNHCR, UN, UNIDO, UNODC, UNUN, UNOPS, UNV, UN, WFP and WHO.
[2] CAT, CED, ICESCR, and CRPD reports and a response under OP CAT.
[3] A/HRC/37/64, paras 51, 52.
[4] https://www.UN.org/EN/HRBodies/OPCAT/Pages/Article17.aspx
[5] "UN lists its global definition of key populations on their website (http://www.UN.org/en/topic/key-populations). In Cambodia's context, they include gay men, men who have sex with men, entertainment workers (sex workers), transgender people, and people who inject drugs.
[6] *Rectangular Strategy Phase III*, para 4: http://www.cdc-crdb.gov.kh/cdc/documents/Rectangular_Strategy_Phase_III.pdf
[7] A/HRC/36/32, para 25.
[8] A/HRC/36/32, para 10.
[9] A/HRC/37/64, para 6.
[10] 'UN Experts say Constitutional changes in Cambodia infringe democracy', Statement of the Special Rapporteur on the situation of human rights in Cambodia and the Special Rapporteur on Freedom of Expression, 20 February 2018.
[11] A/HRC/33/39, para 26. 'UN's Statement on Trade Unions Law in Cambodia', 4 April 2016, http://www.UN.org/asia/media-centre/news/WCMS_466553/lang--en/index.htm ; Observation (CEACR) published 107th ILC Session (2018), Freedom of Association and Protection of the Right to Organize Convention, 1948 (No.87), http://www.UN.org/dyn/normlex/en/f?p=NORMLEXPUB:13100:0::::P13100_COMMENT_ID:3344064
[12] A/HRC/30/39, para 20.
[13] A/HRC/36/32, para 29
[14] A/HRC/33/39, para 32
[15] A/HRC/36/32, paras 26.
[16] A/HRC/36/32, para 32
[17] A/HRC/36/32, para 28
[18] A/HRC/36/32, para 35
[19] A/HRC/37/64, paras 23-24
[20] A/HRC/37/64, paras 8-9.
[21] A/HRC/37/64, para 7.
[22] Speaking Notes of the UNESCO Representative on World Press Freedom Day, 3 May 2017 http://www.unesco.org/new/en/phnompenh/about-this-office/single-view/news/speech_2017_world_press_freedom_day_new_media_new_oppo/
[23] A/HRC/33/39, para 12.
[24] A/HRC/36/32, para 14.
[25] A/HRC/36/32, para 19
[26] A/HRC/37/64, para 9.
[27] A/HRC/33/39, para 9.
[28] A/HRC/36/32, para 17.
[29] A/HRC/36/61, para 5.
[30] A/HRC/37/64, para 5
[31] A/HRC/37/64, para 6.
[32] A/HRC/37/64 para 30
[33] SR's End of mission statement, 14 March 2018: http://cambodia.UN.org/sites/default/files/End%20of%20Mission%20statement%2014%20March%202018.pdf
[34] A/HRC/36/32, para 3
[35] A/HRC/37/64, para 37

[36] A/HRC/36/32, para 3.
[37] A/HRC/36/32, para 3; http://www.cdc-crdb.gov.kh/cdc/donor_country_pro/korea/2017_12_14_Policy_dialogue/docs/NSDP.pdf
[38] A/HRC/37/64, para 37
[39] A/HRC/37/64, para 44-45.
[40] UNDP, FAO, UNEP, UNREDD+, Final Evaluation of the UN-REDD Cambodia National Programme Report, June 2015; USAID-LEAF and FAO, Drivers of Forest Change in the Greater Mekong Subregion Regional Report, 2015; Deluxe, C., Study on Drivers of Change Affecting Mekong Forests, Country report: Cambodia, 2015.
[41] Royal Government of Cambodia, Forest Investment Program Cambodia's Investment Plan, draft for review April 2017, http://www.moe.gov.kh/wp-content/uploads/2017/05/Forest-Investment-Program_Camdodia-Investment-Plan.pdf
[42] Royal Government of Cambodia, National Forest Programme (2010-2029). http://www.cdc-crdb.gov.kh/cdc/documents/Sector_Strategy/6_Forestry_Reform/National_Forest_Programme_2010_2029_Eng.pdf
[43] A/HRC/36/32, para 56.
[44] WHO (2016). Cambodia Health Systems in Transition - Increasing equity in health service access and financing: Health strategy, policy achievements and new challenges, World Health Organization, http://apps.who.int/iris/bitstream/10665/249514/1/WPR-2016-DHS-009.pdf?ua=1
[45] SR's End of mission statement, 18 Aug 2017: https://UN.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=22046&LangID=E
[46] WHO, Global Health Expenditure Database (http://apps.who.int/nha/database/ViewData/Indicators/en)
[47] OECD (2017). Youth Well-being Policy Review of Cambodia, OECD, http://www.oecd.org/countries/cambodia/Youth-well-being-policy-review-Cambodia.pdf.
[48] WHO (2014). Adolescent contraceptive use - Data from the Cambodia Demographic and Health Survey (CDHS) 2014, World Health Organization, http://apps.who.int/iris/bitstream/10665/252421/1/WHO-RHR-16.67-eng.pdf?ua=1.
[49] Minister of Education, Key Note Address, Education Congress, 20 March 2018.
[50] Actual Net Enrolment in primary education 2017-18 is 98.1%, according to EMIS data presented in MoEYS' Education Congress report, published in March 2018, p41.
[51] According to the MoEYS-UNICEF Out of School Children Report, published in 2017, 10 per cent of children of lower secondary school age (12- to 14-year-olds) dropped out of school (11 per cent for boys), substantially higher than the 1 per cent of children of primary school age.
[52] Education Sector Review 2018, June 2018. Report produced by the Education Sector Working Group.
[53] Ministry of Education, Youth and Sport, Education Congress Report, published March 2018.
[54] https://www.unicef.org/cambodia/12681_25291.html
[55] WFP, Fact Sheet: Education 2018
[56] WFP, Fact Sheet: Education 2018
[57] A/HRC/33/62, para 5
[58] A/HRC/33/62, paras 23-24
[59] A/HRC/33/62, paras 18-19
[60] A/HRC/36/61, paras 32 and 34
[61] https://www.UN.org/cambodia/12681_25291.html
[62] 'A Human Rights Approach to Data: Leaving No One Behind in the 2030 Agenda for Sustainable Development' https://www.UN.org/Documents/Issues/HRIndicators/GuidanceNoteonApproachtoData.pdf
[63] A/HRC/36/61, paras 42
[64] A/HRC/36/61, paras 43
[65] A/HRC/36/61, para 43
[66] A/HRC/RES/36/32, para 13
[67] Ministry of Education, Youth and Sport, Ministry of Labour and Vocational Training, Ministry of Social Affairs, Veterans and Youth Rehabilitation, Ministry of Tourism and Ministry of Women's Affairs.